multi cultural communication

REVIEWED September 2004 NSW Multicultural Health Communication Service

KHMER / ខ្មែរ
**November 2001**
**[BHC-5975]**

# តើអ្នកត្រូវការផ្នែកអាសន្ននៃមន្ទីរពេទ្យ – ឬក៏វេជ្ជបណ្ឌិតក្នុងតំបន់អាចជួយអ្នក ?
## Do you need a hospital emergency department - or can your local doctor help ?

វាជាការសំខាន់ដែលប្រជាជនគួរយល់ឲ្យបានច្បាស់លាស់ នូវភារៈកិច្ចនៃ"ផ្នែកអាសន្ននៃមន្ទីរពេទ្យ" (Hospital emergency department), ដែលជាផ្នែកមួយរបស់មន្ទីរពេទ្យសំរាប់ទាក់ទងពិនិត្យមើលនូវពេលមានអាសន្នធ្ងន់ធ្ងរដូចជា គ្រោះថ្នាក់ចរាចរ ឬជម្ងឺគាំងបេះដូង (heart attacks) ព្រមទាំងលក្ខណៈអាសន្នស្រាលជាងនេះ។ ការដឹងនូវរបៀបដែលផ្នែកអាសន្ននៃមន្ទីរពេទ្យធ្វើការ ហើយនិងរបៀបប្រើផ្នែកសេវាផ្សេងទៀត អាចបន្ថយនូវពេលវេលារងចាំ ព្រមទាំងជួយឲ្យអ្នកឆាប់បានទទួលការព្យាបាលផង។ ពេលវេលាដែលត្រូវរងចាំនៅផ្នែកអាសន្ននៃមន្ទីរពេទ្យ គឺយោងទៅតាមសភាពអាសន្នរបស់អ្នក – អ្នកជម្ងឺដែលមានសភាពធ្ងន់ធ្ងរ មានលទ្ធភាពចូលមុនអ្នកជម្ងឺដែលមិនសូវមានភាពអាសន្ន។

### <u>តើកន្លែងណាផ្សេងទៀតដែលខ្ញុំអាចទទួលការព្យាបាលបានឬទេ</u> ?

តាមធម្មតាជនទីមួយដែលអ្នកត្រូវទៅជួបពីបញ្ហាសុខភាពរបស់អ្នក គឺវេជ្ជបណ្ឌិត (General practitioner អក្សរកាត់ GP) ។ វេជ្ជបណ្ឌិតជាច្រើន ធ្វើការនៅក្នុងមណ្ឌលពិនិត្យរោគដែលបើកយូរម៉ោងឬរហូតដល់ ២៤ម៉ោងក្នុងមួយថ្ងៃ។ បើអ្នកទៅជួបវេជ្ជបណ្ឌិតពីបញ្ហាគ្មានភាពអាសន្នជៀសជាងទៅផ្នែកអាសន្ននៃមន្ទីរពេទ្យ អ្នកនឹងចំណាយពេលសំរាប់រងចាំតិចជាងសំរាប់ទទួលការព្យាបាល ហើយម្យ៉ាងទៀតក៏ដូចជាអ្នកបានជួយបន្ថយបន្ទុកនៃផ្នែកអាសន្នរបស់មន្ទីរពេទ្យដែរ។ នៅតាមតំបន់ជាច្រើន ក៏មាន"មណ្ឌលសុខភាពសង្គម" (Community health centres) ដែលមានបុគ្គលិកហ្វឹកហ្វឺនសំរាប់ផ្តល់ជំនាញការបំរើជាច្រើនវិស័យដោយគ្មានគិតតម្លៃ។ ចំពោះពត៌មានបន្ថែមទៀតសូមទាក់ទងទៅ"មណ្ឌលសុខភាពសង្គម" (Community health centre) (ក្នុងសៀវភៅទូរស័ព្ទនៅក្រោមអក្សរ C )។

### <u>តើយ៉ាងដូចម្តេចដែរបន្ទាប់ពីអ្នកបានទៅដល់ផ្នែកអាសន្ននៃមន្ទីរពេទ្យ</u> ?

អ្នកនឹងបានជួប"អ្នកទទួលភ្ញៀវ"(Receptionist) និង"គិលានុបដ្ឋាយិកាម្យ៉ាង" (Triage nurse)។
អ្នកមានសិទ្ធិ សុំយកអ្នកបកប្រែ ដូច្នេះបើកាលណាអ្នកត្រូវការសុំប្រាប់បុគ្គលិកមន្ទីរពេទ្យឲ្យបានដឹងភ្លាម។
"អ្នកទទួលភ្ញៀវ"នឹងសួរអ្នកនូវ

- ប័ណ្ណមេឌីឃែរ (ឬប័ណ្ណសុខភាព Health Care Card បើកាលណាអ្នកមាន)
- ឈ្មោះ, អាស័យដ្ឋាន និងឈ្មោះវេជ្ជបណ្ឌិតរបស់អ្នក។ នេះជាកិច្ចសំរាប់ជួយបុគ្គលិកមន្ទីរពេទ្យសំរាប់លទ្ធភាពមើលប្រវត្តខាងវេជ្ជសាស្រ្តរបស់អ្នកពីមុនមក។

"គិលានុបដ្ឋាយិកាម្យ៉ាង" (Triage nurse) គឺជាឯកទេសខាងសុខភាពដែលបានទទួលការហ្វឹកហ្វឺនពិសេស ហើយដែលមានភារៈកិច្ចសំរាប់ពិនិត្យចាត់ចែងមើលជនរងគ្រោះ ដើម្បីទទួលការព្យាបាលយោងទៅតាមភាពអាសន្នប៉ុនណា។ ដូចវេជ្ជបណ្ឌិតដែរ គិលានុបដ្ឋាយិកានៅក្នុង"ផ្នែកអាសន្ននៃមន្ទីរពេទ្យ" គឺជាអ្នកដែលមានសញ្ញាប័ត្រខ្ពង់ខ្ពស់ និងបានទទួលការហ្វឹកហ្វឺនពិសេសសំរាប់ករណីអាសន្ន។ នៅក្នុងករណីខ្លះ គិលានុបដ្ឋាយិកានឹងចាប់ផ្តើមព្យាបាលអ្នកជម្ងឺមុនពេលបានជួបវេជ្ជបណ្ឌិត។

## <u>**បើខ្ញុំមកផ្នែកអាសន្ននៃមន្ទីរពេទ្យ តើខ្ញុំត្រូវរង់ចាំអស់រយៈពេលប៉ុន្មាន**</u> ?

អ្នកមិនអាចធ្វើការណាត់ជាមុនសំរាប់ជួបវេជ្ជបណ្ឌិតនៅក្នុង“ផ្នែកអាសន្ននៃមន្ទីរពេទ្យ”ទេ។ បើមានអ្នកណាម្នាក់ដែលបានជួបវេជ្ជបណ្ឌិតលឿនជាងអ្នកដ៏ទៃ ក៏ពីព្រោះតែអ្នកនោះឋិតក្នុងសភាពអាសន្នធ្ងន់ធ្ងរជាងប៉ុណ្ណោះ។ ការដែលអ្នកមកមន្ទីរពេទ្យនេះដោយឡានពេទ្យដឹកនាំមកក្តី មិនមែនតែងតែមានន័យថា គេអាចពិនិត្យមើលអ្នកមុននោះឡើយ បើកាលណាមានអ្នកជម្ងឺឯទៀតឋិតនៅក្នុងសភាពអាសន្នជាងនោះ។ មូលហេតុផ្សេងទៀតដែលធ្វើឲ្យមានការរង់ចាំយូរនោះមានដូចជា ៖

- ការរកពត៌មានទាំងអស់ដែលត្រូវការសំរាប់ប្រមាណមើលឲ្យបានពេញលេញនូវលក្ខណៈរបស់អ្នកជម្ងឺ អាចអស់ពេល១ឬ២ម៉ោង។ ឧទាហរណ៍ អ្នកអាចត្រូវថតកាំរស្មី x-rays ឬធ្វើតេស្តដើម្បីឲ្យបានដឹងនូវលក្ខណៈរបស់អ្នក។
- ប្រសិនបើអ្នកត្រូវចូលគេងនៅមន្ទីរពេទ្យ គេអាចត្រូវពេលបីបួនម៉ោងដើម្បីរៀបចំទីកន្លែងគ្រែសំរាប់អ្នក (ក៏ប៉ុន្តែអ្នកនឹងបានទទួលការថែទាំយ៉ាងដិតដល់ក្នុងរយៈនោះ)។

## <u>**តើខ្ញុំគួរធ្វើដូចម្តេចក្នុងរយៈពេលរង់ចាំ**</u> ?

- បើអ្នកជាអ្នកជម្ងឺ បុគ្គលិកពេទ្យអាចប្រាប់អ្នកមិនឲ្យញ៉ាំឬផឹកអ្វីទាំងអស់ រហូតទាល់តែអ្នកបានជួបវេជ្ជបណ្ឌិត។ ប្រសិនបើអ្នករឹតតែមិនស្រួលឬលក្ខណៈរបស់អ្នកប្រែប្រួល (ឬមួយបើអ្នកបានស្រួលឡើងវិញហើយចង់ត្រឡប់ទៅវិញ)សុំប្រាប់ “គិលានុបដ្ឋាយិកាម្យ៉ាង” (Triage nurse) ឲ្យដឹង។
- សុំធ្វើតាមការបង្គាប់របស់បុគ្គលិកពេលមកមន្ទីរពេទ្យ។ ការជួយបុគ្គលិក នឹងធ្វើឲ្យបុគ្គលិកអាចផ្តល់ការមើលថែទាំរឹតតែបានល្អបំផុត។

ចូរចាំទុកក្នុងចិត្តថា “ផ្នែកអាសន្ននៃមន្ទីរពេទ្យ” គឺជាកន្លែងដែលមានភាពតានតឹង ហើយបុគ្គលិកឋិតក្នុងសម្ពាធជុំវិញ ដើម្បីជួយអ្នកជម្ងឺដែលឋិតក្នុងសភាពធ្ងន់ធ្ងរជាងគេ មុន។ ទោះបីអ្នកមានការព្រួយបារម្ភណ៍ ហើយតប់ប្រមល់ព្រោះការរង់ចាំយូរក្តី អាកប្បកិរិយាគំរុះគំរើយឬអំពើកាចសាហាវដល់បុគ្គលិក“ផ្នែកអាសន្ននៃមន្ទីរពេទ្យ” នឹងមិនបណ្តោយឲ្យធ្វើឡើយ។ ការផ្ទុះកំហឹងនិងការរំខានពីអ្នកជម្ងឺឬពីញាតិសន្តាននឹងរឹតតែបណ្តាលឲ្យកាន់តែយឺតយូរថែមទៀត។

## <u>**តើយ៉ាងដូចម្តេចដែរនៅពេលខ្ញុំចាកចេញពី“ផ្នែកអាសន្ននៃមន្ទីរពេទ្យ**</u> ?

មន្ទីរពេទ្យនឹងប្រាប់គម្រោងការណ៍មួយដល់អ្នកជម្ងឺអំពីរបៀបថែទាំ ហើយនឹងពេលដែលត្រូវទៅជួបវេជ្ជបណ្ឌិតក្រោយទៀត។ បើត្រូវការសំបុត្រឈប់សំរាកធ្វើការ ឬសំបុត្របញ្ជាក់ពីលក្ខណៈនិងការព្យាបាលអ្នកជម្ងឺ សុំអ្នកប្រាប់បុគ្គលិកឲ្យដឹងមុនពេលចាកចេញពីមន្ទីរពេទ្យ។

ប្រសិនបើអ្នកមានការពិបាកក្នុងការទូរស័ព្ទជាភាសាអង់គ្លេស សុំអ្នកទាក់ទងទៅផ្នែកផ្តល់អ្នកបកប្រែ Translating and Interpreting Service (អក្សរកាត់ **TIS**) លេខ 131 450។

អ្នកអាចយកពត៌មានផ្នែកសុខភាពបន្ថែមទៀតជាភាសាខ្មែរ ពីកំព្យូទ័រតាមរយៈ **Multicultural Communication website at <http://mhcs.health.nsw.gov.au**

លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ព ក៏ប៉ុន្តែអាចមិនបានកែតម្រូវឲ្យទាន់ការលៈទេសៈ។ លោក-អ្នក ប្រហែលអាចត្រូវមើលបញ្ជាក់លេខនៅក្នុង“សៀវភៅទូរស័ព្ទ”(Telephone Directory)។